ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញា+១) ជំនាន់ទី២២

សម័យប្រឡងថ្ងៃទី ០៥ ខែតុលា ឆ្នាំ ២០១៦

វិញ្ញាសា ៖ ប្រវត្តិវិទ្យា រយៈពេល ៣ម៉ោង

អត្ថាកំណែ

(១.០០) ១. + សន្និវង្សអង្គរ ចាប់ផ្តើមពីរាជ្យ ព្រះបាទជ័យវរ្ម័នទី២(ជយវម្មទី២) នៅក្នុងឆ្នាំ៨០២នៃគ.ស។
+លទ្ធិទេវរាជគឺជាពិធីមួយដែលស្តេចជយវរ្ម័នទី២បានប្រារព្ធឡើងនៅគ.ស៨០២ នៅលើភ្នំគូលែន បំណងធ្វើឲ្យកម្ពុជារួចផុតពីចំណុះជ្វា ព្រមទាំងធ្វើឲ្យទ្រង់មានឋានៈជាស្តេចអាទិទេព និងជាស្តេចចក្រវាល។

២.ចក្រភពអង្គរ ធ្លាក់ចុះដោយសារកត្តា ៖

- ❖ គ្រោះធម្មជាតិ
  -គ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ បានធ្វើឱ្យខូចខាតប្រព័ន្ធធារាសាស្ត្រ
- ❖ ទំនាស់សាសនា
  - ព្រះបាទជ័យវរ្ម័នទី៨គឺប្តូរពីព្រះពុទ្ធសាសនាមហាយាន ទៅព្រហ្មញ្ញសាសនាវិញជាហេតុនាំឱ្យមានការបែកបាក់សាមគ្គីភាពជាតិខ្មែរ ។
  -មួយភាគធំនៃចម្លាក់តាមបុរាណដ្ឋាននានា ដែលឧទ្ទិសចំពោះព្រះពុទ្ធសាសនាត្រូវបានផ្លាស់ប្តូរស្ទើរតែទាំងអស់។
  -ចម្លាក់នៅតាមប្រាសាទនានាជាពិសេសប្រាសាទនាគព័ន្ធ បានបង្ហាញឱ្យឃើញពីការផ្លាស់ប្តូរសាសនាក្នុងរយៈពេលដ៏ខ្លីនាស.វទី១៣នៃគ.ស។
- ❖ សង្គ្រាមជាមួយប្រទេសជិតខាង
  +សង្គ្រាមជាមួយចាម្ប
  -នៅគ.ស១១៣៦ចាម្បបានក្បត់ស្តេចខ្មែរទៅចុះចូលជាមួយយួន ហេតុនេះហើយព្រះបាទស្យវរ្ម័នទី២បានវាយចាម្បបាក់ស្បាតហើយបញ្ចូលក្នុងខេត្តខណ្ឌខ្មែរ។
  -នៅឆ្នាំ១១៧៧ចាម្ប បានកាន់កាប់អង្គរដោយសម្លាប់ស្តេចជ្រែករាជ្យត្រីភូវនាទិត្យវរ្ម័ន។
  +អំពើឃោរឃៅរបស់ពួកម៉ុងហ្គោល នៅសតវត្សទី១៣
  +ការឈ្លានពានរបស់សៀម
  -សៀមវាយត្រួតត្រាក្រុងអង្គរលើកទី១ (១៣៥៣-១៣៥៧)
  -សៀមវាយត្រួតត្រាក្រុងអង្គរលើកទី២ (១៣៩៤-១៤០១)
  -សៀមវាយត្រួតត្រាក្រុងអង្គរលើកទី៣ (១៤២០-១៤២១)
- ❖ សង្គ្រាមក្នុងស្រុក
  -នៅឆ្នាំ១០០២ នៃគ.ស មានសង្គ្រាមក្នុងស្រុកអស់រយៈពេល៩ឆ្នាំ

-ស្តេចគ្រាញ់នៅមហីធរបុរៈខាងជើងភ្នំដងរែក បានផ្តាច់ខ្លួន ប្រកាសឯករាជ្យតាំងខ្លួនជាព្រះបាទជ័យវរ្ម័នទី៦នៅឆ្នាំ១០៧៦។

-នៅគ.ស ១១៦៥ មានការបះបោរដណ្តើមរាជ្យពីព្រះបាទយសោវរ្ម័នទី២

-ការជ្រែករាជ្យពីព្រះបាទជ័យវរ្ម័នទី៨ ដោយបុត្រសុណិសា របស់ទ្រង់

❖ សេដ្ឋកិច្ច

-ដោយសារតែរាជាត្រូវកសាងក្រុងថ្មី ប្រាសាទ ហើយប្រើមនុស្សផ្តោតតែលើទិសដៅសាសនា ខ្វះខាតពេលវេលាក្នុងការកសាងសេដ្ឋកិច្ច។

-ខ្មែរប្តូរទីក្រុងញឹកញាប់នាំឱ្យយឺតយ៉ាវក្នុងការកសាងសេដ្ឋកិច្ច។

-ការជួរជំនឿសាសនា ដោយបំផ្លាញសមិទ្ធផលចាស់ ហើយកសាងសមិទ្ធផលថ្មីនាំឱ្យខាតបង់សេដ្ឋកិច្ច។

-សង្គ្រាមជ្រែករាជ្យនាំឱ្យខូចខាតទ្រព្យសម្បត្តិ និង ពេលវេលាកសាងសេដ្ឋកិច្ចជាដើម

(ន.៤០) ៣. +បដិវត្តន៍ **មីអ៊ីយិ** (Meiji) នៅប្រទេសជប៉ុន គឺជាកំណែទម្រង់ បើកទ្វារចំហយ៉ាងធំទទួលឥទ្ធិពលពីអឺរ៉ុប ដែលចាប់ផ្តើមនៅក្នុងរជ្ជកាលព្រះចៅអធិរាជ មូជីហ៊ីតុ ឬ "អធិរាជ**មីអ៊ីយិ**" (Meiji) ឆ្នាំ១៨៦៨។

+សម័យកាលនេះបាននាំមកដល់ប្រទេសជប៉ុនន្ទវ:

❖ នយោបាយ:

➢ រចនាសម្ព័ន្ធតាមបែបសក្តិភូមិត្រូវលុបបំបាត់

➢ លទ្ធិប្រជាធិបតេយ្យ

➢ រដ្ឋធម្មនុញ្ញ រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ

❖ សេដ្ឋកិច្ច ៖

➢ វិស័យឧស្សាហកម្មត្រូវបានផ្លាស់ប្តូរ ពីការផលិតសម្លៀកបំពាក់ និងទំនិញធុនស្រាល ទៅជាការផលិតគ្រឿងម៉ាស៊ីន និងគ្រឿងសព្វាវុធធុនធ្ងន់។

❖ យោធា ៖

➢ កងទ័ពសាមូរ៉ៃរបស់ជប៉ុន ក៏ត្រូវបានកែប្រែឲ្យទៅជាកងទ័ពទំនើប ដែលមានឯកសណ្ឋាន គ្រឿងសព្វាវុធ និងយុទ្ធសាស្ត្រទ័ពតាមបែបលោកខាងលិច។

➢ កងទ័ពជប៉ុន មានសមត្ថភាព យកឈ្នះកងទ័ពចិន និងកងទ័ពរុស្សី

❖ សង្គម ៖

➢ ប្រកាសសមភាពដល់ប្រជាពលរដ្ឋ

➢ បញ្ចូលការងកិច្ចសិក្សាក្នុងបឋមសិក្សា

➢ រៀបចំតុលាការ

➢ បើកទ្វារទទួលអ្នកប្រាជ្ញបរទេសមកពីគ្រប់ទិសទី ជាពិសេសពីប្រទេសលោកខាងលិច។

*សម្គាល់៖ បើបេក្ខជនសរសេរតែឃ្លាថា (សម័យមីអ៊ីយិ ប្រទេសជ៉ុនបានក្លាយជាមហាអំណាច មានការរីកចម្រើនលូតលាស់ទាន់ប្រទេសទាំងឡាយនៅ ទ្វីបអឺរ៉ុប)ឱ្យ ០,២៥ ពិន្ទុ ។

(ន.០០) ៤ +ការបាត់បង់ទឹកដីកម្ពុជាក្រោមចាប់ផ្តើមឡើងនៅក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី២ (១៦១៩-១៦២៧) ពេលនោះយួនបានខ្ចីទឹកដីខ្មែរ ដោយសន្យាសងវិញក្នុងរយៈពេល៥ឆ្នាំ តែយួនពុំបានធ្វើតាមសន្យា។
+ការបាត់បង់នេះបានចប់សព្វគ្រប់នៅពេលដែលបាត់ឯងបានប្រគល់ឱ្យវៀតណាមនៅថ្ងៃទី០៤ ខែមិថុនាឆ្នាំ១៩៤៩។

៥+មូលហេតុនៃសង្គ្រាមរវាងអ៊ីស្រាអែល និងប៉ាឡេស្ទីន មាន៖

- ជនជាតិជ្វីហ្វ ដែលរស់នៅរាយប៉ាយលើពិភពលោក ចង់បង្កើតរដ្ឋលើទឹកដីកំណើតរបស់ជនជាតិខ្លួន (ប៉ាឡេស្ទីន)
- កេរដំណែលអាណានិគម៖ នៅក្រោយសង្គ្រាមលោកលើកទី១ ចក្រភពអង់គ្លេសទទួលអាណត្តិ(ម៉ាន់ដាត)គ្រប់គ្រងលើទឹកដីប៉ាឡេស្ទីន បន្ទាប់ពីអាណាចក្រអូតូម៉ង់ដួលរលំ។ មកដល់ឆ្នាំ១៩៤៧ អង់គ្លេសបានប្រកាសបញ្ចប់អាណត្តិរបស់ខ្លួននៅលើទឹកដីប៉ាឡេស្ទីន ដោយមិនបានកំណត់ច្បាស់លាស់ថា តើទឹកដីប៉ាឡេស្ទីននឹងត្រូវចាត់ចែងបង្កើតជារដ្ឋយ៉ាងដូចម្តេចនោះទេ ដោយបានរុញសំណុំរឿងនេះទៅឲ្យអង្គការសហប្រជាជាតិជាអ្នកដោះស្រាយ។
- ការបង្កើតរដ្ឋអ៊ីស្រាអែល លើទឹកដីប៉ាឡេស្ទីន ៖ នៅទីបំផុត គឺដំណោះស្រាយបង្កើតរដ្ឋឯករាជ្យពីរដាច់ពីគ្នា ដែលត្រូវបានមហាសន្និបាត អ.ស.បអនុម័ត នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៤៧ (សេចក្តីសម្រេចលេខ ១៨១) អនុម័តដោយសំឡេងគាំទ្រលើសពី ២ភាគ៣ ក៏ប៉ុន្តែគ្រប់បណ្តាប្រទេសអារ៉ាប់ និងប្រទេសកាន់សាសនាអ៊ីស្លាមទាំងអស់បាននាំគ្នាបោះឆ្នោតប្រឆាំង។
- ការប្រឆាំងនឹងការបង្កើតរដ្ឋអ៊ីស្រាអែល លើទឹកដីប៉ាឡេស្ទីន៖ រដ្ឋអ៊ីស្រាអែលត្រូវបានប្រកាសជាផ្លូវការ នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៤៨។ មួយថ្ងៃក្រោយការប្រកាសបង្កើតរដ្ឋអ៊ីស្រាអែល បណ្តាប្រទេសអារ៉ាប់ ដែលនៅជុំវិញនោះ គឺរួមមាន អេហ្ស៊ីប ស៊ីរី ហ្សកដានី លីបង់ និងអ៊ីរ៉ាក់ ក៏បាននាំគ្នាលើកទ័ពចេីកការវាយប្រហារលើអ៊ីស្រាអែល។
- ប៉ាឡេស្ទីនចង់បង្កើតរដ្ឋឯករាជ្យមួយ តែត្រូវជំទាស់ដោយអ៊ីស្រាអែលវិញម្តង
- អ៊ីស្រាអែលចេះតែបន្ត និងពង្រីកអាណានិគមទៅលើទឹកដីរបស់ប៉ាឡេស្ទីន

+សង្គ្រាម៦ថ្ងៃនៅមជ្ឈិមបូព៌ា គឺជាសង្គ្រាមរវាងប្រទេសអ៊ីស្រាអែល និងបណ្តាប្រទេសអារ៉ាប់ ដែលមានរយៈពេល៦ថ្ងៃ គឺចាប់ផ្តើមនៅថ្ងៃទី៥ដល់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៦៧។

(ន.០០) ៦.រដ្ឋប្រហារទម្លាក់សម្តេចសីហនុគឺ ជាមូលហេតុដែលធ្វើឲ្យកម្ពុជាធ្លាក់ចូលក្នុងភ្លើងសង្គ្រាមឥណ្ឌូចិន។
+សង្គ្រាមឥណ្ឌូចិនជាសង្គ្រាមដែលបានកើតឡើងក្នុងប្រទេសបី៣គឺ កម្ពុជា វៀតណាម ឡាវ នៅសតវត្សរ៍ទី២០។ សង្គ្រាមនេះមានបីលើកគឺលើកទី១ រវាងបារាំងនិងវៀតណាម(១៩៤៦-១៩៥៤)លើកទី២ រវាងសហរដ្ឋអាមេរិក និងវៀតណាម(១៩៥៤-១៩៧៥) និងលើកទី៣ កើតឡើងនៅប្រទេសកម្ពុជា ដែលសង្គ្រាមនេះគេហៅថាសង្គ្រាមតំណាង។

+មូលហេតុដែលនាំឲ្យមានរដ្ឋប្រហារឆ្នាំ១៩៧០៖

-សង្គ្រាមត្រជាក់៖ មនោគមន៍វិជ្ជាពីរគឺសេរីនិងកុំមុយនីសអូសទាញកម្ពុជាឲ្យធ្លាក់ចូលក្នុងសង្គ្រាម

-វិបត្តិសង្គម៖ អំពើពុករលួយ បក្សពួកនិយម ល្បែងស៊ីសង។

-វិបត្តិសេដ្ឋកិច្ច៖ដួលរលំរោងចក្រ សហគ្រាសរដ្ឋ បណ្តាលមកពីអំពីពុករលួយ បក្សពួក ការផ្តាច់ជំនួយសេដ្ឋកច្ចពីអាមេរិក។

-វិបត្តិនយោបាយ៖ នយោបាយអព្យាក្រឹតមិនចំទិសបណ្តាលមកពីមនោគមវិជ្ជាពីរ។

-វត្តមានជនជាតិបរទេស៖ ពួកវៀតមិញ ពួកវៀតកុងបានចូលមករស់នៅក្នុងប្រទេសកម្ពុជាកាន់តែច្រើនជាពិសេសយួនបានចូលមកនៅគ្រប់ខេត្តក្រុង។

+មេដឹកនាំសំខាន់ៗនៃសាធារណៈរដ្ឋខ្មែរមាន៖

-លន់ នល់ -សិរិមត:

-សឺងង៉ុក ថាញ់ -ចេង ហោង

-ហង្ស ធុនហាក់

-អ៊ិន តាំ

-ឡុងបូរ៉ែត

*សម្គាល់៖ -បើបេក្ខជនឆ្លើយត្រូវបួនឈ្មោះឡើងបានពិន្ទុ0.៥0

-បើឆ្លើយត្រូវក្រោមបួនឈ្មោះបាន 0.២៥

ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញា+១) ជំនាន់ទី២៣

សម័យប្រឡងថ្ងៃទី ០១ ខែតុលា ឆ្នាំ ២០១៧

ឥរិយាបថ ៖ ប្រវត្តិវិទ្យា រយៈពេល ៣ម៉ោង

អត្ថាកំណែ

១. ព្រះសានបុរជារាជធានីកម្ពុជាក្នុងសម័យចេនឡា (៥៥០-៨០២ ឆ្នាំនៃគ.ស)។

នៅទីនោះមានប្រាសាទចំនួនប្រមាណជាង១៨០ ដោយចែកជាបីក្រុមធំៗ និងក្រុមប្រាសាទតូចៗផ្សេងទៀត៖

- ក្រុមប្រាសាទខាងជើង ៖ ហៅថាប្រាសាទសំបូរ នៅកណ្តាល និងព័ទ្ធជុំវិញដោយប្រាសាទតូចៗ ហើយប្លែកៗគ្នា ដូចជា ប្រាសាទសំបូរ ប្រាសាទប្រនាក់សី ប្រាសាទរបងរមាស ប្រាសាទស្រីគ្រប់លក្ខណ៍ ប្រាសាទខ្នីសែ... ។
- ប្រាសាទកណ្តាល ៖ ហៅថាប្រាសាទតោ ប្រាង្គប្រាសាទកណ្តាលមានទ្វារចូលពីទិសខាងជើង ឯទ្វារបើកពីទិសមួយទៀតជាទ្វារបញ្ឆោត។ នៅភាគខាងលិចនៃប្រាសាទតោ មានក្រុមប្រាសាទតូចៗជាច្រើនទៀត ដូចជា ប្រាសាទតោ ប្រាសាទម៉ាអត ប្រាសាទតាមាន... ។
- ក្រុមប្រាសាទខាងត្បូង ៖ ហៅថា ប្រាសាទយាយព័ទ្ធ ឬប្រាសាទនាគព័ទ្ធ ដែលស្ថិតនៅចំកណ្តាលហ៊ុំព័ទដោយប្រាសាទ ជាច្រើន មានកំពែងពីរជាន់ ដែលកំពែងខាងក្នុងមាន គោបុរៈ ចូលទាំងបួនទិស។ ក្រុមប្រាសាទទាំងនេះជា អតីតរាជធានី ដូចជា ប្រាសាទយាយព័ទ្ធ ប្រាសាទប្រាង្គ ប្រាសាទសូតិច ប្រាសាទភ្នំចាដែល ប្រាសាទគោកក្របិច ប្រាសាទគគំទ្រែង ... ។
  - និងក្រុមប្រាសាទតូចៗមានដូចជា ក្រុមប្រាសាទក្រាលរមាស និងក្រុមប្រាសាទត្រពាំងរពាក់។ល។ និងប្រាសាទមួយចំនួនទៀតដូចជា ប្រាសាទព្រៃ ប្រាសាទអារាមឥសី ប្រាសាទបុសរាម...។

និងប្រាសាទ ផ្សេងៗទៀត

២.ប្រាសាទបាយ័ន ឬអង្គរធំ គឺជាប្រាសាទបែបពុទ្ធសាសនា។

មូលហេតុនៃការគោរពពុទ្ធសាសនានាពេលនោះ ៖

- នៅមុនរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៧ តើតមាននូវកុប្បកម្ម ការបះបោរ និងទំនាស់រាជ្យសម្បត្តិ ជាហេតុធ្វើឱ្យមានភាពចលាចល និងអស្ថិរភាពសង្គម
- ការលុកលុយក្រុងអង្គរដោយកងទ័ពចាម្បានៅឆ្នាំ១១៧៧ ជាអន្លង់មួយយ៉ាងធ្ងន់វាយទៅលើលទ្ធិទេវរាជ
- ប្រជាជនលែងជឿទៅលើប្រសិទ្ធភាពនៃលទ្ធិទេវរាជ ក្នុងព្រហ្មញ្ញសាសនា
- ប្រជាជនជាច្រើនបានក្លាយជាពុទ្ធសានិក រួចស្រេចទៅហើយ ក្នុងខណៈដែលមន្ត្រីរាជវាំងជឿលើព្រហ្មញ្ញសាសនា
- ដើម្បីស្រោចស្រង់ជាតិឱ្យមានពន្លឺឡើងវិញបន្ទាប់ពីការឈ្លានពានរបស់ចាម្ប នាឆ្នាំ១១៧៧
- ព្រះបាទជ័យវរ្ម័នទី៧(១១៨១-១២២១) ទ្រង់បានខិតខំរកមធ្យោបាយការពារក្រុង តាមបែបពុទ្ធសាសនាមហាយាន ដែលទ្រង់យល់ថាមានប្រសិទ្ធភាពជាងសាសនារបស់រាជាមុនៗ
- ព្រះបាទជ័យវរ្ម័នទី៧ ទ្រង់ពឹងផ្អែកទៅលើព្រះពោធិសត្វ "អវលោកេស្វរៈ" ដែលពោរពេញដោយធម៌មេត្តា ករុណា ហើយប្រមើលមើលសុខទុក្ខរបស់សត្វលោក

- លទ្ធិពុទ្ធសាសនាជាលទ្ធិបែបមនុស្សនិយម មានចំនោរទៅរកជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជារាស្ត្រទូទៅ
- ព្រះបាទជ័យវរ្ម័នទី៧ ជាអ្នករំដោះក្រុងអង្គរពីចាម្ប៉ា ទ្រង់មានមហេសីព្រះនាងជ័យរាជទេវី និងព្រះនាងឥន្ទ្រទេវី ដែលសុទ្ធតែជាអ្នកជ្រះថ្លាក្នុងពុទ្ធសាសនា
- ចំពោះប្រជារាស្ត្រវិញ លទ្ធិពុទ្ធសាសនាមហាយាន មានសមត្ថភាពស្រោចស្រង់ ការពារ និងបម្រើរាស្ត្រ

៣.+មូលហេតុដែលធ្វើឱ្យកម្ពុជាធ្លាក់ចូលក្នុងភ្លើងសង្គ្រាមក្នុងឆ្នាំ១៩៧០៖

- ឥទ្ធិពលនៃសង្គ្រាមត្រជាក់(១៩៤៧-១៩៩១) គឺការប្រជែងឥទ្ធិពលគ្នារវាងអាមេរិក និងសូវៀត
- ការអនុវត្តនយោបាយអព្យាក្រឹតរបស់សម្តេច នរោត្តមសីហនុ(១៩៥៥-១៩៧០) មិនបានសម្រេចគោលដៅ
- រដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដោយសេនាប្រមុខលន់ នល់
- អំពើពុករលួយ បក្សពួកនិយម កុប្បកម្មពេញផ្ទៃប្រទេស
- ការជ្រៀតជ្រែករបស់វៀតណាម ចិន និងសហរដ្ឋអាមេរិក ក្នុងនយោបាយខ្មែរ
- ការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជារបស់ព្រះបាទនរោត្តម សីហនុ ឆ្នាំ១៩៧០
- ការគាំទ្ររបស់អាមេរិកចំពោះរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ របស់លោកសេនាប្រមុខលន់ នល់
- ការគាំទ្ររបស់ចិនចំពោះ រណសិរ្សរបស់សម្តេចនរោត្តម សីហនុ និងក្រុមខ្មែរក្រហម

និងចំណុចផ្សេងៗទៀត

+ពលរដ្ឋកម្ពុជា ត្រូវចងចាំពីមេរៀនប្រវត្តិសាស្ត្រ ពីសង្គ្រាមស៊ីវិល និងឥទ្ធិពលមនោគមវិជ្ជានយោបាយ៖

- **សង្គម**
  - ខូចខាតហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ ផ្ទះសម្បែង
  - ការសម្លាប់រង្គាល ការស្លាប់បាត់បង់ជីវិតរបស់ប្រជាជន
  - ការបែកបាក់គ្រួសារ ប្រពន្ធ ប្តី
  - បន្សល់ទុកនូវក្មេងកំព្រា ស្ត្រីមេម៉ាយ
  - ការរស់នៅដោយការភិតភ័យ និងគ្មានសិទ្ធិសេរី
  - បាត់បង់ឱកាសការងារ ការអប់រំ និងសុខភាព
- **នយោបាយ**
  - ការបែកបាក់ផ្ទៃក្នុង និងការជ្រៀតជ្រែកពីបរទេស នាំឱ្យប្រទេសជាតិរងគ្រោះមហន្តរាយ និងភាពវឹកវរ នយោបាយផ្ទៃក្នុង
  - អស្ថិរភាពនយោបាយ អសន្តិសុខសង្គម
  - ប្រទេសបាត់បង់កិត្តិយស បាត់បង់កិច្ចានុភាព
- **សេដ្ឋកិច្ច**
  - ការធ្លាក់ចុះនៃសេដ្ឋកិច្ច អតិផរណា វិបត្តិហិរញ្ញវត្ថុ

- ដីស្រែចម្ការ ត្រូវទំនេរចោល ខូចខាតផលដាំណាំ
- ឧស្សាហកម្មពុំមានដំណើរការ
- ពាណិជ្ជកម្មត្រូវរះស្ទះ

➢ **បាត់បង់ឱកាស**

- ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច កសាងសង្គម
- ការរួបរួមជាតិ និងការពារជាតិ
- ចូលរួមក្នុងឆាកអន្តរជាតិ ដោយសមភាព
- ទទួលយកវិនិយោគទុនពីបរទេស

និងចំណុចផ្សេងៗទៀត

៤. +ក្រោយសង្គ្រាមលោកលើកទី២ ប្រទេសនៅទ្វីបអឺរ៉ុបត្រូវបានបែងចែកជាពីរផ្នែក គឺអឺរ៉ុបខាងកើត និងអឺរ៉ុបខាងលិច។

+ការបែងចែកនេះដោយសារមូលហេតុជាច្រើន ដូចជា៖

➢ ឥទ្ធិពលនៃសង្គ្រាមលោកលើកទី២(១៩៣៩-១៩៤៥)៖

- នៅក្នុងសង្គ្រាមប្រទេសនៅទ្វីបអឺរ៉ុបភាគច្រើនគ្រប់គ្រងដោយអាល្លឺម៉ង់
- នៅចុងបញ្ចប់នៃសង្គ្រាមប្រទេសនៅទ្វីបអឺរ៉ុបមួយចំនួន ត្រូវរំដោះដោយសូវៀត និងអាមេរិក
- សេដ្ឋកិច្ចទ្វីបអឺរ៉ុបចុះទន់ខ្សោយ ងាយទទួលរងឥទ្ធិពល អឺរ៉ុបត្រូវពឹងផ្អែកលើជំនួយអាមេរិក និងសូវៀត

➢ សន្ធិសីទក្រុងយ៉ាល់តា និងសន្ធិសីទ ពតស្តាំ(Potsdam) ឆ្នាំ១៩៤៥ ស្តីពីការបែងចែកទ្វីបអឺរ៉ុបក្រោយសង្គ្រាមលោកលើកទី២

- ការបែងចែកទឹកដីអាល្លឺម៉ង់ដោយមហាអំណាចទាំងបួន ជាបួនតំបន់កាន់កាប់
- ការបែងចែកទីក្រុងប៊ែរឡាំងជាបួនផ្នែក
- ភាពទ័លច្រកផ្នែកនយោបាយ និងភាពប្រៃសាគ្នា នៃមហាអំណាចសម្ព័ន្ធមិត្ត ដែលធ្វើឱ្យដំណោះស្រាយពីបញ្ហាអាល្លឺម៉ង់ ត្រូវបរាជ័យ

➢ ការប្រជែងគ្នារបស់មហាអំណាចពីរគឺ សហរដ្ឋអាមេរិក និងសហភាពសូវៀត

- នៅក្នុងសង្គ្រាម មហាអំណាចសហរដ្ឋអាមេរិក អង់គ្លេស និងសហភាពសូវៀត បានរួបរួមគ្នាប្រយុទ្ធប្រឆាំងនឹងណាស៊ីអាល្លឺម៉ង់ តែមហាអំណាចទាំងនេះមានលក្ខណៈប្លែកគ្នាទាំងស្រុងទាំងផ្នែកមនោគមវិជ្ជានយោបាយ និងសេដ្ឋកិច្ច
- ការមិនទុកចិត្តគ្នារវាងសហរដ្ឋអាមេរិក និងសហភាពសូវៀតនៅចុងបញ្ចប់នៃសង្គ្រាម
- ការប្រជែងមនោគមវិជ្ជា នយោបាយ បែបប្រជាធិបតេយ្យសេរី និងកុម្មុយនិស្ត
- ការប្រជែងផ្នែកសេដ្ឋកិច្ច តាមបែបមូលធននិយម និងសង្គមនិយម
- ការប្រជែងផ្នែកសព្វាវុធ អាវុធនុយក្លេអ៊ែរ ព្រមទាំងការប្រជែងបច្ចេកវិជ្ជា និងការទូត

- នៅចុងសង្គ្រាមឥទ្ធិពលកុម្មុយនិស្តបានរីករាលដាលយ៉ាងរហ័សនៅអឺរ៉ុប ធ្វើឱ្យមានការប្រជែងពីអាមេរិក
- អឺរ៉ុបបែកខាងកើតត្រូវរំដោះដោយសូវៀតក្នុងអំឡុងឆ្នាំ១៩៤៤-១៩៤៥ បានធ្លាក់ក្រោមឥទ្ធិពលកុម្មុយនិស្តសូវៀត និងក្រោយមកប្រកាន់យកបបកុម្មុយនិស្តតាមបែបសូវៀត
- អឺរ៉ុបខាងលិចត្រូវបានរំដោះដោយអង់គ្លេស និងអាមេរិកក្នុងអំឡុងឆ្នាំ១៩៤៤-១៩៤៥ បានប្រកាន់យកបបប្រជាធិបតេយ្យសេរី

➢ ទ្រីស្តីទ្រូម៉ាន់ និងផែនការម៉ាសាល ឆ្នាំ១៩៤៧ ៖ អាមេរិក អនុវត្តនយោបាយទប់ទល់ និងរុញច្រានបបកុម្មុយនិស្ត

និងចំណុចផ្សេងៗទៀត

៥.កត្តាដែលនាំឱ្យកម្ពុជាអាចបញ្ចប់សង្គ្រាមបាន ហើយងាកមករកការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមវិញ មាន៖

+កត្តាខាងក្រៅ

- កំណែទម្រង់របស់លោកមីខាអ៊ីល ហ្គោបាស្ចូវ នៅសហភាពសូវៀត នាពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៨០
- ការដួលរលំនៃរបបកុម្មុយនិស្តនៅអឺរ៉ុបខាងកើត នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ និងបន្តបន្ទាប់
- ជំនួបកំពូលរវាងសហរដ្ឋអាមេរិក និងសហភាពសូវៀតឆ្នាំ១៩៨៧ បានធ្វើឱ្យស្ថានការណ៍នយោបាយនៅកម្ពុជាប្រសើរជាងមុន
- ការផ្តាច់ជំនួយរបស់សូវៀតចំពោះប្រទេសវៀតណាម នាចុងទសវត្សរ៍ឆ្នាំ១៩៨០
- ការដកកងទ័ពវៀតណាមចេញពីប្រទេសកម្ពុជានាឆ្នាំ១៩៨៩
- ការដួលរលំនៃអតីតសហភាពសូវៀត ឆ្នាំ១៩៩១
- ការបញ្ចប់នៃសង្គ្រាមត្រជាក់ ឆ្នាំ១៩៩១
- អន្តរាគមន៍របស់បរទេសបានធ្វើឱ្យភាគីជម្លោះខ្មែរយល់ព្រមចូលតុចរចា
- ការជួយជ្រោមជ្រែងពីសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ជាពិសេសថៃ និងឥណ្ឌូនេស៊ី ក្នុងការរៀបចំដំណើរការសន្តិភាព រហូតទទួលបានកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ២៣ តុលា ១៩៩១
- ការរៀបចំការបោះឆ្នោតឆ្នាំ១៩៩៣ ដោយអង្គការសហប្រជាជាតិ

+កត្តាក្នុងស្រុក និងមេដឹកនាំខ្មែរ (ឆន្ទៈបង្រួបបង្រួមជាតិ)

-ថ្ងៃទី ២ ធ្នូ ១៩៨៧ មានការជួបគ្នាលើកទី១ នៅហ្សែអង់តាដឺន៍រ ប្រទេសបារាំងរវាង

-ការចរចាលើកទី ២ នៅខែ មករា ឆ្នាំ ១៩៨៨ នៅបារាំង រវាង សីហនុហ៊ុន សែន-

- រដ្ឋាភិបាលក្រុងភ្នំពេញធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ នៅឆ្នាំ១៩៨៩

-ចាប់ពីឆ្នាំ ១៩៨៩មក វេទិការបស់សម្តេចសីហនុ និង លោក ហ៊ុន សែន ដើម្បីស្វែងរក ដំណោះស្រាយវិបត្តិនយោបាយនៅកម្ពុជាបានប្រព្រឹត្តទៅជាបន្តបន្ទាប់ នៅទីក្រុងប៉ារីស ប្រទេសបារាំង ទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ទីក្រុងតូក្យូ ប្រទេសជប៉ុន និងទីក្រុងប៉ាតាយ៉ាប្រទេសថៃ

- ថ្ងៃទី១០ កញ្ញា ១៩៩០ បង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ SNC សម្តេចសីហនុប្រធាន

- ថ្ងៃទី២៣-២៤ មិថុនា ១៩៩១ នៅទីក្រុងប៉ាតាយ៉ា គូបដិបក្ខខ្មែរទាំងបួន បានជួបជុំគ្នា និងបានចុះសម្រុងគ្នាអំពីគម្រោងការដោះស្រាយបញ្ហាជាតិ

- ថ្ងៃទី២៣ តុលា ១៩៩១ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៖ ភាគីជម្លោះបានចាប់ដៃគ្នា យល់ព្រមធ្វើការបោះឆ្នោតជាសកលដែលមានអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជាដែលហៅកាត់ថាអ៊ុនតាក់)UNTAC) មើលការទទួលខុសត្រូវ។

- នៅឆ្នាំ១៩៩៣ រៀបចំការបោះឆ្នោតជាសកល ដោយសេរី និងយុត្តិធម៌នៅកម្ពុជា

+ ការផ្សះផ្សាជាតិក្រោយឆ្នាំ ១៩៩៣ និង នយោបាយឈ្នះ-ឈ្នះ

-ការបង្កើតរដ្ឋាភិបាលចម្រុះក្រោយការបោះឆ្នោត

-ធ្វើការទប់ស្កាត់មិនឱ្យពួកខ្មែរក្រហមវិលត្រឡប់មកកាន់អំណាចវិញ

-ខេត្តប៉ៃលិនបានចុះចូលជាមួយរដ្ឋាភិបាលនាថ្ងៃទី ២២ ខែតុលា ឆ្នាំ១៩៩៦ និងទីកន្លែងដទៃទៀតដូចជា សំឡូត កំរៀង ភ្នំក្រឹក្ស សំពៅលូន និងតំបន់ម៉ាឡៃ បានចុះចូលជាបន្តបន្ទាប់

- ការអនុវត្តនយោបាយឈ្នះ-ឈ្នះរបស់សម្តេចហ៊ុន សែន ទទួលបានជោគជ័យទាំងស្រុងនៅចុងឆ្នាំ ១៩៩៨ និងដើមឆ្នាំ១៩៩៩ ដោយ ក្រុមខ្មែរក្រហមបានធ្វើសមាហរណកម្មទាំងស្រុងជាមួយ រដ្ឋាភិបាល។

និងចំណុចផ្សេងៗទៀត